## ព័ត៌មានស្តីពី

## "សិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើកម្មវិធីព្រៃឈើជាតិ"

### ១. សេចក្តីផ្តើម

មាត្រាទី ៩ នៃ ច្បាប់ស្តីពី ព្រៃឈើបានចែងថា រដ្ឋបាលព្រៃឈើត្រូវរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិដោយមានការចូលរួមទូលំទូលាយពីគ្រប់អង្គធរពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន។ ជាមួយគ្នានេះ សូចនាករតាមដានរួម (JMI) ស្តីពីកំណែទំរង់ព្រៃឈើដែលបានអនុម័តរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍបានកំណត់ក្នុងគោលដៅទី ៩ ចំណុចទី ៤ ថា : រៀបចំបញ្ចប់ កម្មវិធីព្រៃឈើជាតិក្នុងខែ កញ្ញា ឆ្នាំ ២០០៩ និងចាប់ផ្តើមអនុវត្តនៅដំណាច់ឆ្នាំ ២០០៩។

ក្នុងខែ មិនា ឆ្នាំ២០០៩ កន្លងមកថ្មីៗនេះ ជាមួយជំនួយថវិកាពីអង្គការ Danida/Dfid/NZAid និង NFP Facility/FAO រដ្ឋបាលព្រៃឈើបានទទួលជោគជ័យលើការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកម្មវិធីព្រៃឈើជាតិនៅតាមភូមិភាគព្រៃឈើទាំងបួន ក្នុងទូទាំងប្រទេស។ ដើម្បីធ្វើឱ្យសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ មានខ្លឹមសារ កាន់តែប្រសើរអាចអនុវត្តបានប្រកបដោយប្រសិទ្ធិភាព និង ឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន រដ្ឋបាល ព្រៃឈើនឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់សាធារណៈមួយទៀតនៅថ្នាក់ក្រោមជាតិ ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី៤-៥ ខែមិថុនា ឆ្នាំ២០០៩** នៅសណ្ឋាគារ ភ្នំប្រុស នាទីក្រុងកំពង់ចាម ខេត្តកំពង់ចាម។

### ២. គោលបំណង

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈនេះ មានគោលបំណងដើម្បីបង្កើនការយល់ដឹងនិង ប្រមូលយកនូវមតិកែលំអពីបណ្តាភាគីពាក់ព័ន្ធ លើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ និង កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ។ រដ្ឋបាលព្រៃឈើនឹង អញ្ជើញអ្នកចូលរួមសរុបចំនួន ១៥០ នាក់ មកពីក្រសួងមន្ទីរពាក់ព័ន្ធ សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន វិស័យឯកជន ព្រះសង្ឃ អ្នកសារព័ត៌មាន អង្គការក្រៅរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍នានា។ នៅថ្ងៃទី ១ នៃអង្គសិក្ខាសាលានឹងមានបទបង្ហាញ និងការចាប់អារម្មណ៍ពីតំណាងភាគីពាក់ព័ន្ធនានា ហើយនៅថ្ងៃទី ២ នឹងមានការពិភាក្សាលើឯកសារទាំងពីរខាងលើ ។

### ៣. អំពីការស្នាក់នៅ និង អាហារ

អ្នកដែលត្រូវបានអញ្ជើញចូលរួម (មានលិខិតអញ្ជើញ) ទាំងឡាយណាដែលពុំមានការឧបត្ថម្ភពីអង្គភាព ស្ថាប័ន អង្គការរបស់ខ្លួន នឹងត្រូវទទួលបានការឧបត្ថម្ភសំរាប់ការស្នាក់នៅ អាហារ និង ការធ្វើដំណើរ តាមការកំណត់របស់អង្គការ Danida ។ ដោយឡែកអ្នកដែលធ្វើការនៅទីរួមខេត្តកំពង់ចាម ពុំបានទទួលបានការឧបត្ថម្ភទេ។ អ្នកចូលរួមទាំងអស់ ***ត្រូវទទួលខុសត្រូវ ក្នុងការស្វែងរកកន្លែងស្នាក់នៅ អាហារ និង ការធ្វើដំណើររៀងៗខ្លួន***។

### ៤. ទំនាក់ទំនង

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងបណ្ឌិត សុខ ហេង **០១២ ៦៣៩៩៦១ ឬ លោក សុខ ស៊្រុន ០១២ ៩៤០៩៣៦**